# ការអនុវត្តជាក់ស្តែងនៃ
# ការបែងចែកមត៌ក Ⅰ

ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្ត្រាចារ្យ UMEMOTO Yumi

# ដីកាសម្រេចបែងចែកមត៌ក

- សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន នៅពេលមរណភាពរបស់មតកជន (ម១១៤៥ ក១, ម១១៤៧)។
- ត្រូវបែងចែកមត៌កដើម្បីរំលាយទំនាក់ទំនងអវិភាគនៃមត៌ក (ម១១៤៨) និង កំណត់ឲ្យច្បាស់លាស់នូវទ្រព្យសម្បត្តិដែលទទួលបាន។
- សហសន្តតិជនអាចចាប់ផ្តើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ខែបានកន្លងផុត ក្រោយពីការចាប់ផ្តើមសន្តតិកម្ម (ម១២៦៦)។
- បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការអាចធ្វើការបែងចែកមត៌កនោះ តាមពាក្យសុំរបស់សហសន្តតិជន (ម១២៧០ និង តារាងឧបសម្ព័ន្ធផ្នែកទី៥ ចំណុចទី១៧ ដែលយោងតាម ម៣ ក១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

# លំហូរនៃការវិនិច្ឆ័យ

១. ទំហំនៃសន្តតិជន-ចំណែកសន្តតិកម្មតាមច្បាប់

↓

២. ទំហំនៃមត៌ក

↓

៣. ការវាយតម្លៃមត៌ក

↓

៤. កំណត់ចំណែកមត៌កជាក់ស្តែង

↓

៥. ដីកាសម្រេចអំពីវិធីបែងចែក

# ១. ទំហំនៃសន្តតិជន-ចំណែកសន្តតិកម្មតាមច្បាប់

I. សហព័ទ្ធ

II. ញាតិលោហិតដែលជាសន្តតិជន

i. កូន និង សន្តតិជនជំនួសរបស់កូន (ម១១៥៦ ម១១៥៧)

ii. បច្ឆាញាតិផ្ទាល់ (ម១១៥៩)

iii. បងប្អូនបង្កើត និងសន្តតិជនជំនួសរបស់បងប្អូនបង្កើត (ម១១៦០ ម១១៥៧)

# អានុភាពនៃការបែងចែកមត៌កដោយអវត្តមានសន្តតិជន

- ការបែងចែកមត៌កដោយអវត្តមានសន្តតិជនមួយចំនួន គឺមោឃភាព។
- សន្តតិជនដែលមិនបានចូលរួមបែងចែកមត៌ក អាចទាមទារឲ្យធ្វើបដិទានសន្តតិកម្ម ចំពោះបុគ្គលដែលបានធ្វើលទ្ធកម្មមត៌កបាន (ម១៣០១)
- ការទាមទារឲ្យធ្វើបដិទានសន្តតិកម្ម នឹងផុតអាជ្ញាយុកាលក្នុងអំឡុងពេល ៥ឆ្នាំ គិតចាប់ពីពេលបានផ្ទេរមត៌កទៅឲ្យភាគីម្ខាងទៀត ដោយការបែងចែកមត៌ក (ម១៣០៤)។

※ ចំណុចដែលបញ្ជាក់អំពីទំហំនៃសន្តតិជន គឺមិនមានន័យក្នុងផ្លូវច្បាប់ទេ។

→ ត្រូវដោះស្រាយតាមនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ជាអាទិ៍។

# ២. ទំហំនៃមត៌ក

## I. ការស្រាវជ្រាវមត៌ក

មត៌កដែលជាកម្មវត្ថុនៃការបែងចែក គឺជាទ្រព្យសកម្មដែលមិនទាន់បានបែងចែកនៅឡើយនៅពេលបែងចែកមត៌ក នៅក្នុងចំណោមសិទ្ធិនិងករណីយកិច្ចដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជននៅពេលចាប់ផ្តើមសន្តតិកម្ម (ម១១៤៧ ក១)។

## II. បញ្ហានៃការបញ្ចូល ឬមិនបញ្ចូលជាមត៌ក

i. ក្នុងករណីដែលមានវិវាទពាក់ព័ន្ធនឹងការបញ្ចូល ឬ មិនបញ្ចូលទ្រព្យសម្បត្តិណាមួយជាមត៌ក ជាទូទៅគេតែងអនុវត្តតាមនីតិវិធីរដ្ឋប្បវេណីជាមុន ពីព្រោះជាចុងក្រោយបញ្ហានេះនឹងត្រូវដោះស្រាយតាមនីតិវិធីរដ្ឋប្បវេណី។

ii. ចំណុចដែលត្រូវប្រុងប្រយ័ត្នពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

ទាក់ទងនឹងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ គឺមានតែចំណែកកម្មសិទ្ធិអវិភាគរបស់មតកជនប៉ុណ្ណោះដែលក្លាយជាមត៌ក។

# ២.ទំហំនៃមត៌ក

III. បញ្ហាចំពោះការក្លាយជាកម្មវត្ថុ ឬ មិនមែនជាកម្មវត្ថុនៃការបែងចែកមត៌ក

i. សិទ្ធិលើបំណុលជាប្រាក់

ជាទូទៅសិទ្ធិលើបំណុលនេះនឹងបែងចែកទៅតាមចំណែកនៃសន្តតិកម្មតាមច្បាប់ ប៉ុន្តែ បើសិនជាមានការព្រមព្រៀងរវាងសន្តតិជន សិទ្ធិលើបំណុលនោះអាចជាកម្មវត្ថុនៃការបែងចែក។

ii. កាតព្វកិច្ច

មិនមែនជាកម្មវត្ថុនៃការបែងចែកមត៌កនោះទេ។

IV. វត្ថុជំនួស ជាអាទិ៍ (ម១២៧២)

i. ផលពីសិទ្ធិនៃមត៌ក

ii. ប្រាក់សំណងការខូចខាតជាអាទិ៍ដែលបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬ ការបំពានកម្មវត្ថុនៃមត៌ក

iii. ប្រាក់លក់ដែលបានធ្វើលទ្ធកម្មជាអាទិ៍ ដោយកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ

# ៣.ការវាយតម្លៃអចលនទ្រព្យ

I. វិធីវាយតម្លៃ

- វាយតម្លៃ
- ប្រសិនបើមានការព្រមព្រៀងអំពី ចំនួននៃការវាយតម្លៃ វិធីវាយតម្លៃ គេអាចសម្រេចតាមការព្រមព្រៀងនោះបាន។

II. អចលនវត្ថុ

- នៅប្រទេសជប៉ុន តុលាការអាចបង្គាប់ឲ្យដាក់ឯកសារដូចជា លិខិតវាយតម្លៃអចលនវត្ថុ លិខិតប្រកាសពន្ធសន្តតិកម្ម និង លិខិតវាយតម្លៃរបស់ក្រុមហ៊ុនអចលនវត្ថុធំៗ ដើម្បីសម្របសម្រួលយោបល់របស់ភាគី និង ឈានទៅដល់ការព្រមព្រៀង។
- ក្នុងករណីដែលមិនអាចព្រមព្រៀងគ្នាទេ តុលាការនឹងជ្រើសរើសអ្នកវាយតម្លៃដែលជាបុគ្គលមានចំណេះដឹងដូចជាអ្នកជំនាញវាយតម្លៃអចលនវត្ថុជាដើម មកឲ្យវាយតម្លៃ។

# ៤.ការកំណត់ចំណែកសន្តតិកម្មជាក់ស្តែង

I. ចំណែកសន្តតិកម្មជាក់ស្តែង គឺជាអត្រាចំណែកមត៌កចុងក្រោយដែលបានសម្រួលរួចរាល់ ដោយពិចារណាលើចំណែកសន្តតិកម្មតាមច្បាប់ជាមួយនឹងការទទួលផលប្រយោជន៍ពិសេស (ម១១៦៣) និង ភាគនៃវិភាគទាន (ម១១៦៦) ។

II. ការសម្រួលចំណែកសន្តតិកម្ម

i. មត៌កដែលត្រូវមាន គឺជាមត៌កនៅពេលចាប់ផ្តើមសន្តតិកម្មបូកនឹងផលប្រយោជន៍ពិសេស និង ដកភាគនៃវិភាគទានចេញ (ទ្រព្យដែលត្រូវបានចាត់ទុកថាជាមត៌ក)។

ii. ចំណែកសន្តតិកម្មរបស់សន្តតិជនទាំងអស់ (ចំណែកសន្តតិកម្មបណ្តោះអាសន្ន) ត្រូវគណនាឲ្យទៅតាមចំណែកសន្តតិកម្មតាមច្បាប់នៃទ្រព្យដែលត្រូវបានចាត់ទុកថាជាមត៌កក្នុងចំណុច i.។

iii. ចំពោះជនដែលទទួលបានផលប្រយោជន៍ពិសេស ត្រូវទទួលបានចំណែកមត៌កជាក់ស្តែងស្មើនឹងចំណែកមត៌កបណ្តោះអាសន្នចំណុច ii. ដក ផលប្រយោជន៍ពិសេសដែលទទួលបានចេញ ហើយសន្តតិជនដែលទទួលបានវិភាគទាន ត្រូវទទួលបានចំណែកមត៌កជាក់ស្តែងស្មើនឹងចំណែកមត៌កបណ្តោះអាសន្នចំណុច ii. បូក នឹងភាគនៃវិភាគទាន។

# ៥.ដីកាសម្រេចអំពីវិធីបែងចែក

I. ប្រភេទនៃវិធីបែកចែក

i. ការបែងចែកវត្ថុ (វត្ថុផ្ទាល់)

វិធីបែងចែកដោយបែងចែកវត្ថុផ្ទាល់

ii. ការបែងចែកតាមការសងជំនួស (ម១២៦៧ ក២)

វិធីបែងចែកដោយឲ្យសន្តតិជនណាមួយធ្វើលទ្ធកម្មលើទ្រព្យសម្បត្តិលើសពីចំណែកនៃសន្តតិកម្មតាមច្បាប់ ដោយត្រូវបង់ប្រាក់សម្រួលទៅតាមសមាមាត្រនៃចំណែកឲ្យសន្តតិជនផ្សេងទៀត។

iii. ការបែងចែកដោយប្តូរជាប្រាក់ (ម១២៧១)

វិធីបែងចែកដោយលក់មត៌ក ហើយបែងចែកប្រាក់ថ្លៃលក់នោះ (លក់ដោយស្មគ្រ័ចិត្ត លក់ដោយបង្ខំ)

iv. ការបែងចែកដោយអវិភាគ

វិធីដែលឲ្យសន្តតិជនធ្វើលទ្ធកម្មដោយអវិភាគតាមបញ្ញត្តិសិទ្ធិប្រត្យក្ស (ម២០២) ទៅតាមចំណែកសន្តតិកម្មជាក់ស្តែងនៃមត៌ក

→ បណ្តឹងទាមទារឲ្យបែងចែកវត្ថុអវិភាគ (ម២១២)

# ៥.ដីកាសម្រេចអំពីវិធីបែងចែក

II. កត្តាត្រូវពិចារណា (ម១២៧០ ក២)

i. ប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាពរបស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត (ម១២៦៧ ក១)

a. ប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក

ខាងលើនេះគឺជាខ្លឹមសារនៃមត៌ក។ វិធីបែងចែកគឺមានភាពខុសគ្នាទៅតាមករណីនីមួយៗដូចជា ករណីមានតែអចលនវត្ថុ ឬ ករណីទ្រព្យសម្បត្តិចរន្តក្រៅពីអចនលវត្ថុ ជាអាទិ៍។

b. មុខរបរ

ចំពោះសន្តតិជនដែលទទួលមុខរបរបន្តពីគ្រួសារ តុលាការភាគច្រើនបង្គាប់ឲ្យសន្តតិជននោះធ្វើលទ្ធកម្មនូវអចលនវត្ថុ ឬ ភាគហ៊ុនដែលចាំបាច់សម្រាប់ដំណើរការមុខរបរ។

c. អាយុ និង ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត

ចំពោះជនជរា យុវជន ជនមានកាយសម្បទាមិនគ្រប់គ្រាន់ តុលាការត្រូវពិចារណាចំពោះបុគ្គលទាំងនោះ។

d. ស្ថានភាពជីវភាព និងស្ថានភាពផ្សេងទៀត

ស្ថានភាពនៃការប្រើប្រាស់មត៌កតាំងពីដើមមកជាអាទិ៍ក៏ត្រូវយកមកពិចារណា។

# ៥.ដីកាសម្រេចអំពីវិធីបែងចែក

II. កត្តាត្រូវពិចារណា (ម១២៧០ ក២)

ii. សិទ្ធិអាទិភាពរបស់សហព័ទ្ធ (ម១២៦៨)

នៅក្នុងការបែងចែកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ សហព័ទ្ធមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគរបស់មតកជន រហូតដល់គ្រប់ចំនួននៃចំណែកសន្តតិកម្ម។

iii. សំណងនៃកាតព្វកិច្ចរបស់មតកជន (ម១២៦៩)

កាតព្វកិច្ចមិនមែនជាកម្មវត្ថុនៃដីកាសម្រេចអំពីការបែងចែកមត៌កនោះទេ ហើយសន្តតិជនត្រូវទទួលបន្តតាមចំណែកនៃសន្តតិកម្មតាមច្បាប់ ហេតុនេះសន្តតិជនត្រូវបែងចែកមត៌កដោយពិចារណាពីការណ៍ដែលខ្លួនត្រូវសងកាតព្វកិច្ចនោះ។

iv. ទំនៀមទម្លាប់នៅក្នុងតំបន់ និង មតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន (ម១២៧០ ក២)

តុលាការគួរតែគោរពតាមឆន្ទៈរបស់សន្តតិជនតាមតែអាចធ្វើទៅបាន។

# ៥.ដីកាសម្រេចអំពីវិធីបែងចែក

III. ការស្រាវជ្រាវពីវិធីបែងចែកជាក់ស្តែង

i. ការសម្របសម្រួលចំពោះការបែងចែកវត្ថុ

យោងតាមបំណងរបស់សន្តតិជនគ្រប់រូប និង ពិចារណាលើកត្តាដែលត្រូវពិចារណាខាងលើ តុលាការអាចបង្គាប់ឲ្យសន្តតិជននីមួយៗធ្វើលទ្ធកម្មតាមទំហំជាក់ស្តែងនៃចំណែកសន្តតិកម្មរៀងៗខ្លួនលើវត្ថុដែលជាមត៌កបាន។

ii. ការប្រើប្រាស់រួមគ្នាតាមវិធីនៃការបែងចែកវត្ថុ និងការបែងចែកតាមការសងជំនួស

មានករណីជាច្រើនដែលតុលាការប្រើប្រាស់រួមគ្នាបន្ថែមពីលើចំណុច i. ដោយបង្គាប់ឲ្យសន្តតិជនដែលទទួលបានមត៌កលើសពីចំណែកមត៌កជាក់ស្តែង បង់ប្រាក់សម្រួលដែលស្មើនឹងចំនួនដែលលើសនោះ។

III. ការបែងចែកដោយប្តូរជាប្រាក់

ចំពោះវត្ថុដែលគ្មានសន្តតិជនណាចង់ធ្វើលទ្ធកម្ម តុលាការនឹងបែងចែកដោយប្តូរជាប្រាក់។ នៅក្នុងចំណុច ii. ប្រសិនបើសន្តតិជននោះគ្មានធនធានគ្រប់គ្រាន់សម្រាប់បង់ប្រាក់សម្រួលឲ្យសន្តតិជនផ្សេងទៀតទេ ក៏តុលាការអាចធ្វើការបែងចែកដោយប្តូរជាប្រាក់បានដែរ ប្រសិនបើមិនអាចជៀសវៀងបាន ។

iv. ការបែងចែកដោយអវិភាគ

ក្នុងករណីដែលជម្រើសនៃការបែងចែកចំណុច i.~iii. មិនអាចធ្វើបាន តុលាការអាចសម្រេចខុសពីធម្មតាដោយបែងចែកអវិភាគ។

# ឧទាហរណ៍

X ស្លាប់, ប្រពន្ធ A, គ្មានកូន, ម្តាយ B, បងប្រុស C

ដីលំនៅឋាន (ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ) ប្រាក់ក្នុងកុង និង រថយន្ត










# ១.ទំហំនៃសន្តតិជន-ចំណែកសន្តតិកម្មតាមច្បាប់

I. X បានទទួលមរណភាពនៅថ្ងៃទី... ខែ...ឆ្នាំ.... ហើយសន្តតិកម្មបានចាប់ផ្តើម។ សន្តតិជនរួមមាន ប្រពន្ធA និងម្តាយ B របស់មតកជន។

II. ចំណែកសន្តតិកម្មតាមច្បាប់ A បាន ១ភាគ២ និង B បាន ១ភាគ២។

## ២. ទំហំនៃមត៌ក
## ៣.ការវាយតម្លៃមត៌ក

មត៌ករបស់មតកជនមាននៅក្នុងបញ្ជីសារពើភ័ណ្ឌ ១ ដល់ ៣ ។

បញ្ជីសារពើភ័ណ្ឌ

1 អចលនវត្ថុ

ទីតាំងស្ថិតនៅ ភូមិ....... ឃុំ..........ស្រុក........ខេត្ត.......... ទំហំ ............ម៉ែ

លេខប័ណ្ណ ............

លេខក្បាលដី ..............

(ការវាយតម្លៃ ៣00,000$) (ប៉ុន្តែ មត៌កមានតែចំណែកអវិភាគ ១ ភាគ ២)

2 ប្រាក់ក្នុងកុង ធនាគារឈ្មោះ........ សាខា...........កុងសន្សំធម្មតា (គណនីលេខ.......)
៨៥.000$

3 រថយន្ត ស្លាកលេខរថយន្ត.......លេខតួ.......... (ការវាយតម្លៃ ៥000$)

# ៤.កំណត់ចំណែកមត៌កជាក់ស្តែង

（300,000×1/2＋85,000＋5,000）×1/2＝120,000$

A: 120,000$

B: 120,000$

# ៥.ដីកាសម្រេចអំពីវិធីបែងចែក

## I. សាវតា និង ឆន្ទៈរបស់ភាគី ជាអាទិ៍

### i. អំពី A

- A ជាបុគ្គលិកធ្វើការក្នុងក្រុមហ៊ុន មានប្រាក់ខែសម្រាប់ទ្រទ្រង់ជីវភាព ព្រមទាំងមានប្រាក់សន្សំលើសពី ១00,000$។
- A បានរស់នៅក្នុងផ្ទះដែលជាមត៌កក្នុងរឿងក្ដីនេះជាមួយ X រយៈពេល ១0ឆ្នាំហើយ។
- A បានប្រើប្រាស់រថយន្តដែលជាមត៌កក្នុងរឿងក្ដីនេះជាប្រចាំថ្ងៃ។
- A មានបំណងធ្វើលទ្ធកម្មតែម្នាក់ឯងលើចំណែកអវិភាគនៃដី និង រថយន្តដែលជាមត៌កក្នុងរឿងក្ដីនេះ។

### ii. អំពី B

- B មានវ័យចំណាស់ ហើយកំពុងរស់នៅជាមួយ C។ គាត់មានជីវភាពមិនសូវធូធារទេ និងរស់នៅពឹងផ្អែកលើប្រាក់សោធននិវត្តន៍។
- B មានបំណងធ្វើលទ្ធកម្មលើប្រាក់ក្នុងកុង។ ហើយចង់ឲ្យលក់អចលនវត្ថុ និង រថយន្តដែលជាមត៌កក្នុងរឿងក្ដីនេះ ហើយបែងចែងប្រាក់។

# ៥.ដីកាសម្រេចអំពីវិធីបែងចែក

## II. ការពិចារណាអំពីវិធីបែងចែក

- អចលនវត្ថុនៃរឿងក្តីនេះជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ហើយ A មានចំណែកអវិភាគ ១ភាគ២។ A អាចធ្វើលទ្ធកម្មដោយអាទិភាពលើចំណែកអវិភាគនៃអចលនវត្ថុនៃរឿងក្តីនេះ រហូតដល់គ្រប់ចំណែកសន្តតិកម្មបាន (ម១២៦៨)។
- A បានរស់នៅលើអចលនវត្ថុ និង ប្រើប្រាស់រថយន្តនៃរឿងក្តីនេះ ចាប់តាំងពី X នៅរស់មក។
- A មានធនធានគ្រប់គ្រាន់ដើម្បីបង់ប្រាក់សម្រួល។ ប៉ុន្តែ B មើលទៅដូចជាគ្មានធនធានគ្រប់គ្រាន់នោះទេសម្រាប់បង់ប្រាក់សម្រួល។

→ ហេតុនេះ គួរតែឲ្យ B ធ្វើលទ្ធកម្មលើប្រាក់ក្នុងកុង ហើយ A ធ្វើលទ្ធកម្មលើអចលនវត្ថុ និង រថយន្តនៃរឿងក្តីនេះ និងបង់ប្រាក់សម្រួលដែលទទួលបានលើសវិញ។

A: ចំនួនលទ្ធកម្ម អចលនវត្ថុ (ចំណែកអវិភាគ ១ភាគ២) រថយន្ត→155,000$

B: ចំនួនលទ្ធកម្ម ប្រាក់ក្នុងកុង 85,000$

ប្រាក់សម្រួល 155,000－120,000＝35,000$

# ដីកាសម្រេច

សេចក្តីសម្រេចបញ្ចប់

សម្រេចបែងចែកមត៌ករបស់មតកជនដូចខាងក្រោម៖

១.អ្នកដាក់ពាក្យសុំ A ធ្វើលទ្ធកម្មចំណែកអវិភាគ ១ភាគ២នៃអចលនវត្ថុដូចក្នុងបញ្ជីសារពើភ័ណ្ឌ១ និង រថយន្តដូចក្នុងបញ្ជីសារពើភ័ណ្ឌ៣។

២.ភាគីម្ខាងទៀត B ធ្វើលទ្ធកម្មប្រាក់ក្នុងកុងដូចក្នុងបញ្ជីសារពើភ័ណ្ឌ២។

៣.បង្គាប់ឲ្យអ្នកដាក់ពាក្យសុំ A បង់ប្រាក់ចំនួន 35,000$ ដែលជាប្រាក់សម្រួលនៃលទ្ធកម្មមត៌កខាងលើឲ្យទៅភាគីម្ខាងទៀត។

# អរគុណ